អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន
# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ
# ទាក់ទងសំណុំរឿង ០០៤

សហព្រះរាជអាជ្ញាអន្តរជាតិ លោក អាន់ឌ្រូ ឃេលី ធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈនេះ អនុលោមតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក និង វិធាន ២១.គ និង ៥៤ នៃវិធានផ្ទៃក្នុង ដើម្បីឲ្យប្រាកដថា សាធារណជនបានជ្រួតជ្រាបយ៉ាងត្រឹមត្រូវអំពីកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដែលកំពុងតែប្រព្រឹត្តទៅក្នុងសំណុំរឿងលេខ០០៤ ដោយមានការយកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់ជនរងគ្រោះ និងសាក្សី, សិទ្ធិរបស់ជនសង្ស័យ និងលក្ខខណ្ឌតម្រូវនានានៃកិច្ចស៊ើបសួរ ។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ក្នុងសំណុំរឿង០០២ អង្គបុរេជំនុំជម្រះ បានសម្រេចថា សហចៅក្រមស៊ើបអង្កេតបានជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដោយវិធាន ២១.១.គ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ក្នុងការធ្វើឲ្យជនរងគ្រោះទទួលបាននូវព័ត៌មាន ស្តីពីឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមការស៊ើបសួរ "ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី" ហើយថាវាមិនមានលក្ខណៈគ្រប់គ្រាន់ដោយការគ្រាន់តែធ្វើដូច្នេះ "នៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ" នោះទេ ។ ដូចដែល អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងដូច្នោះដែរ ដើម្បីឲ្យ "សិទ្ធិជាសារវន្តរបស់ជនរងគ្រោះ" ត្រូវបាន "ធានាឲ្យបានត្រឹមត្រូវ" នោះសហចៅក្រមស៊ើបអង្កេតត្រូវតែផ្តល់នូវ "ព័ត៌មានឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា... ដល់ជនរងគ្រោះក្នុងអំឡុងពេលនៃដំណាក់កាលមុនសវនាការ" ។ គោលបំណងនៃលក្ខខណ្ឌតម្រូវនេះ គឺដើម្បីធានាថាជនរងគ្រោះមានឱកាសសមស្រប ដើម្បីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើឧក្រិដ្ឋកម្មជាក់លាក់នានា ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរក្នុងករណីជាក់លាក់ណាមួយ ។

អនុលោមតាមសេចក្តីសំរេចរបស់អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើមួយ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ ដោយសូមស្នើដោយគោរពដល់សហចៅក្រមស៊ើបអង្កេតសុំឲ្យចេញជាសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ ត្រឹមថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១ ដោយរៀបរាប់ពីឧក្រិដ្ឋកម្ម និងបទល្មើសនានាដែលកំពុងស្ថិតក្នុងកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿងលេខ ០០៤ ៕